សំណើ
# 38 អនុញ្ញាតឱ្យចេញសញ្ញាប័ណ្ណកម្ចីសម្រាប់ការស្រាវជ្រាវវេជ្ជសាស្ត្រនៃផ្នែកប្រព័ន្ធស៊ុំវិទ្យា។ លក្ខន្តិកៈតាមរយៈគំនិតផ្តួចផ្តើម។

## ★ អំណះអំណាងដែលគាំទ្រសំណើទី 38 ★

អ្នកតស៊ូមតិដើម្បីអ្នកជំងឺ វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងអ្នកស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ អំពាវនាវឱ្យបោះឆ្នោត "បាទ/ចាស" លើសំណើទី 38

អ្នកតស៊ូមតិឈានមុខគេដើម្បីអ្នកជំងឺ រួមមាន សមាគម Alzheimer's, មូលនិធិ Michael J. Fox, សមាគមគិលានុបដ្ឋាកអាមេរិក \California, សមាគម ALS, សមាគមជាតិជំងឺពិការប្រព័ន្ធសរសៃប្រសាទMS និងមូលនិធិជំងឺមហារីកក្រពេញប្រូស្តាត សុទ្ធតែ អំពាវនាវឱ្យបោះឆ្នោត បាទ/ចាស លើសំណើទី 38 ព្រោះវាអាចជួយសង្គ្រោះជីវិតរបស់អ្នក និងជីវិតរបស់មនុស្សដែលអ្នកស្រឡាញ់។

*"ខ្ញុំស្ទើរតែបាត់បង់ជីវិតទៅហើយ នៅសល់តែប៉ុន្មានសប្តាហ៍ទៀតប៉ុណ្ណោះ មុនពេលរបកគំហើញនៃការព្យាបាលដោយប្រព័ន្ធភាពស៊ាំថ្មីបានផ្តល់ឱកាសទីពីរឱ្យខ្ញុំ។ បោះឆ្នោត បាទ/ចាស លើសំណើទី 38 ព្រោះគ្រប់គ្រួសារដែលកំពុងប្រឈមមុខនឹងការធ្វើរោគវិនិច្ឆ័យដ៏ធ្ងន់ធ្ងរស័ក្តិសមនឹងទទួលបានក្តីសង្ឃឹមដូចគ្នានេះ។"*
—Laurie Adami, អ្នកដែលរស់រានពីជំងឺមហារីក និងជាអ្នកតស៊ូមតិដើម្បីអ្នកជំងឺ,Los Angeles

បោះឆ្នោត បាទ/ចាស លើសំណើទី 38 — ដើម្បីព្យាបាល និង បង្ការជំងឺតាមរយៈការស្រាវជ្រាវផ្នែកប្រព័ន្ធភាពស៊ាំដែលអាចជួយសង្គ្រោះជីវិតបាន

សំណើទី 38 ពន្លឿនការអភិវឌ្ឍន៍របកគំហើញវិធីព្យាបាល សម្រាប់ជំងឺដែលប៉ះពាល់ស្ទើរតែគ្រប់គ្រួសារ។ យ៉ាងហោចណាស់ពាក់កណ្តាលនៃមូលនិធិទាំងអស់ ត្រូវបានចាត់ចែងជាពិសេសសម្រាប់ការស្រាវជ្រាវអំពីជំងឺមហារីក ជំងឺបេះដូង និងជំងឺ Alzheimer's។

*"វិទ្យាសាស្ត្រប្រព័ន្ធភាពស៊ាំប្រើប្រាស់ប្រព័ន្ធភាពស៊ាំរបស់រាងកាយដើម្បីរកមើល និងបញ្ឈប់ជំងឺនានា។ សព្វថ្ងៃនេះ របកគំហើញការព្យាបាលដោយប្រព័ន្ធភាពស៊ាំ កំពុងព្យាបាលជំងឺមហារីកមួយចំនួនឱ្យជាសះស្បើយរួចហើយ ដូចជា មហារីកស្បែកដែលកម្រនឹងសាហាវ មហារីកសួត និងជំងឺមហារីកគ្រាប់ឈាម។ ការស្រាវជ្រាវដ៏មានសក្តានុពលកំពុងត្រូវបានអនុវត្ត ដើម្បីបង្ការជំងឺ ដូចជា ជំងឺ Parkinson's ជំងឺបេះដូង ជំងឺទឹកនោមផ្អែម និងជំងឺផ្សេងៗទៀត។"*
— Mark Davis, Ph.D., សមាជិកនៃបណ្ឌិតសភាវិទ្យាសាស្ត្រជាតិ និងបណ្ឌិតសភាវេជ្ជសាស្ត្រជាតិ

*"មនុស្សម្នាក់ក្នុងចំណោមប្រាំបួននាក់ដែលមានអាយុលើសពី 65 ឆ្នាំ កំពុងរស់នៅជាមួយជំងឺ Alzheimer's ប៉ុន្តែបច្ចុប្បន្ននេះ មិនទាន់មានវិធីព្យាបាលណាមួយដែលមានប្រសិទ្ធភាពឡើយ។ បាទ/ចាស លើសំណើទី 38ផ្តល់ក្តីសង្ឃឹមពិតប្រាកដថាអាចស្វែងរកការព្យាបាល និងវិធីឱ្យជាសះស្បើយ សម្រាប់អ្នកជំងឺរាប់លាននាក់ និងគ្រួសាររបស់ពួកគេ ដែលកំពុងរស់នៅជាមួយជំងឺ Alzheimer's និងជំងឺវង្វេង"*
—Susan Disney Lord, ប្រធានក្រុមប្រឹក្សាភិបាលនៃ Alzheimer's Los Angeles

ជួយប៉ះប៉ូវផលប៉ះពាល់ពីការកាត់បន្ថយមូលនិធិសហព័ន្ធសម្រាប់ការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ

ការកាត់បន្ថយមូលនិធិសហព័ន្ធយ៉ាងច្រើន និងភាពមិនច្បាស់លាស់ កំពុងរំខានដល់ការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រដែលមានសារៈសំខាន់យ៉ាងខ្លាំង នៅតាមវិទ្យាស្ថានស្រាវជ្រាវមិនរកប្រាក់កម្រៃ និង សាកលវិទ្យាល័យ ដែលនាំឱ្យមានការពន្យារពេលឆ្ពោះទៅរកវិធីព្យាបាលដែលអាចជួយសង្គ្រោះជីវិត។

សំណើទី 38 បង្កើតប្រភពមូលនិធិដែលមានស្ថិរភាព សម្រាប់របកគំហើញការស្រាវជ្រាវផ្នែកប្រព័ន្ធភាពស៊ាំ។ មូលនិធិទាំងអស់ត្រូវបានចាត់ចែងផ្តាច់មុខសម្រាប់សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវមិនរកប្រាក់ចំណេញដែលមានមូលដ្ឋាននៅរដ្ឋ California — ដើម្បីជួយឱ្យរដ្ឋ California ឈានមុខគេក្នុងប្រទេសជាតិខាងការច្នៃប្រឌិតថ្មីផ្នែកវេជ្ជសាស្ត្រ ជំរុញកិច្ចសហការរវាងអ្នកវិទ្យាសាស្ត្រ និង សាកលវិទ្យាល័យឈានមុខគេ និង បង្កើតការងារដែលមានប្រាក់ចំនូលខ្ពស់រាប់ម៉ឺនកន្លែង។

*"ការព្យាបាលដោយប្រព័ន្ធភាពស៊ាំកំពុងតែផ្លាស់ប្តូរអនាគតនៃការថែទាំអ្នកជំងឺមហារីក។ សំណើទី 38 នឹងជួយពន្លឿនការអភិវឌ្ឍវិធីព្យាបាលដែលអាចជួយសង្គ្រោះជីវិត ខណៈពេលពង្រឹងតួនាទីរបស់ California ក្នុងនាមជាអ្នកដឹកនាំសកលក្នុងការច្នៃប្រឌិតថ្មីផ្នែកវេជ្ជសាស្ត្រ។"*
—Gina Carithers, ប្រធាន និងនាយកប្រតិបត្តិ, មូលនិធិជំងឺមហារីកក្រពេញប្រូស្តាត

ជួយកាត់បន្ថយការចំណាយលើសេវាថែទាំសុខភាពសម្រាប់ប្រជាជននៅរដ្ឋ California

ការព្យាបាលឱ្យជាសះស្បើយ ឬការព្យាបាលដោយប្រព័ន្ធភាពស៊ាំណាមួយដែលត្រូវបានអភិវឌ្ឍតាមរយៈ សំណើទី 38 ត្រូវតែផ្តល់ជូនអ្នកជំងឺនៅនៅក្នុងតម្លៃបញ្ចុះ 20%។ ការបង្ការ និងព្យាបាលជំងឺធ្ងន់ធ្ងរដែលជាបញ្ហាបន្ទាន់បំផុតអោយជាសះស្បើយ ក៏នឹងជួយកាត់បន្ថយការចំណាយលើសេវាថែទាំសុខភាពក្នុងរយៈពេលវែង និង ជួយសន្សំប្រាក់រាប់សិបពាន់លានដុល្លារសម្រាប់រដ្ឋ និង គ្រួសារ ដោយកាត់បន្ថយការចំណាយលើការព្យាបាលដែលអាចជៀសវាងបាន។

គណនេយ្យភាពយ៉ាងរឹងមាំ និង ការការពារអ្នកជាប់ពន្ធ

សំណើទី 38 ត្រូវបានរៀបចំឡើងដោយរ៉ាប់រងការចំណាយរបស់ខ្លួន ដោយមិនបង្កើតការចំណាយសុទ្ធបន្ថែមសម្រាប់រដ្ឋ ឬអ្នកជាប់ពន្ធនានា។ ដប់ភាគរយនៃប្រាក់ចំណូលពីការផ្តល់អាជ្ញាបណ្ណសម្រាប់គ្រូពេទ្យដែលព្យាបាលដោយប្រព័ន្ធភាពស៊ាំដែលទទួលបានជោគជ័យ ត្រូវតែប្រគល់ត្រឡប់ទៅរដ្ឋ California ដើម្បីទូទាត់ចំណាយលើមូលបត្របំណុល រួមទាំងការប្រាក់។ សំណើទី 38 ក៏រួមបញ្ចូលនូវលក្ខខណ្ឌតម្រូវដ៏តឹងរ៉ឹងលើគណនេយ្យភាពផងដែរ រួមមាន៖

- កំណត់ការចំណាយរដ្ឋបាលរបស់រដ្ឋមិនឱ្យលើស 2%
- ការបង្ហាញជាសាធារណៈអំពីការចំណាយ
- ការធ្វើសវនកម្មហិរញ្ញវត្ថុដោយឯករាជ្យ
- សាជីវកម្មដែលរកប្រាក់ចំណេញមិនមានសិទ្ធិទទួលមូលនិធិជាជំនួយទេ

បាទ/ចាស លើសំណើទី 38៖ ទទួលបានការគាំទ្រពីវេជ្ជបណ្ឌិត គិលានុបដ្ឋាក និង អ្នកតស៊ូមតិសម្រាប់អ្នកជំងឺ

• សមាគម ALS• សមាគម Alzheimer's • សមាគមគិលានុបដ្ឋាកអាមេរិក/California • អង្គការរួបរួមដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺមហារីកឈាម • សម្ព័ន្ធជំងឺមហារីកពោះវៀនធំរដ្ឋ California • សម្ព័ន្ធជំងឺថ្លើម• មូលនិធិ Michael J. Fox• សមាគមជាតិជំងឺពិការប្រព័ន្ធសរសៃប្រសាទMS • សមាគមជំងឺ Parkinson រដ្ឋ California ខាងជើង... និងជាច្រើនទៀត។

បាទ/ចាស លើសំណើទី 38 អាចជួយសង្គ្រោះជីវិតរបស់អ្នក និងមនុស្សដែលអ្នកស្រឡាញ់។ សូមបោះឆ្នោត បាទ/ចាស។

*www.YesOn38.com*

**Susan Disney Lord**, ប្រធានក្រុមប្រឹក្សាភិបាល
Alzheimer's Los Angeles

**Eugene P. Brandon**, Ph.D., ក្រុមប្រឹក្សាត្រួតពិនិត្យ
សមាគម ALS

**Dr. Brian Shuch**, M.D., សមាជិកក្រុមប្រឹក្សាភិបាល
សមាគមជំងឺមហារីកតម្រងនោម

## ★ ការបដិសេធចំពោះអំណះអំណាងដែលគាំទ្រសំណើទី 38 ★

រដ្ឋ California គួរតែបន្តក្នុងការគាំទ្រការស្រាវជ្រាវផ្នែកជីវវេជ្ជសាស្ត្រ។ មនុស្សគ្រប់រូបសង្ឃឹមថានឹងមានការព្យាបាលថ្មីៗសម្រាប់ជំងឺបេះដូង ជំងឺមហារីក ជំងឺ Alzheimer's និងជំងឺធ្ងន់ធ្ងរផ្សេងៗទៀត។ ខ្ញុំក៏សង្ឃឹមដូច្នេះដែរ។ ប៉ុន្តែសំណើទី 38 មិនមែនជាមធ្យោបាយត្រឹមត្រូវដើម្បីសម្រេចគោលដៅនោះទេ។

ការអះអាងថាសំណើទី 38 នឹងអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីរ៉ាប់រងការចំណាយរបស់ខ្លួន គឺមិនទាន់មានភាពប្រាកដប្រជានោះទេ។ ការធ្វើសវនកម្ម ការបង្ហាញព័ត៌មានជាសាធារណៈ និងការកំណត់ការចំណាយរដ្ឋបាល ជួយលើកកម្ពស់គណនេយ្យភាព ប៉ុន្តែវាមិនអាចធានាបានថា ការវិនិយោគលើការស្រាវជ្រាវនឹងបង្កើតផលចំណេញផ្នែកសេដ្ឋកិច្ចបានគ្រប់គ្រាន់ ដើម្បីទូទាត់ការសងបំណុលមូលបត្របំណុលដែលមានទឹកប្រាក់រាប់ពាន់លានដុល្លារនោះទេ។

រដ្ឋ California កំពុងបន្តប្រឈមមុខនឹងរចនាសម្ព័ន្ធឱនភាពថវិកា។ សំណើទី 38 នឹងតម្រូវឱ្យមានការសងបំណុលមូលបត្របំណុលប្រមាណ $8.4 ពាន់លាន។ យោងតាមការិយាល័យអ្នកវិភាគផ្នែកនិតិបញ្ញត្តិ ដែលគ្មាននិន្នាការគណបក្ស អ្នកជាប់ពន្ធនឹងត្រូវទទួលបន្ទុកបង់បំណុលប្រមាណ $500 លានក្នុងមួយឆ្នាំ សម្រាប់រយៈពេល 25 ឆ្នាំខាងមុខ។ កាតព្វកិច្ចហិរញ្ញវត្ថុរយៈពេលវែងនោះ នឹងធ្វើឱ្យភាពបត់បែនផ្នែកហិរញ្ញវត្ថុរបស់រដ្ឋក្នុងការឆ្លើយតបទៅនឹងអាទិភាពដែលមានការផ្លាស់ប្តូរកាន់តែមានកម្រិត។

ទន្ទឹមនឹងនេះ សកម្មភាពថ្មីៗរបស់រដ្ឋបាល Trump បានធ្វើឱ្យការផ្តល់មូលនិធិសម្រាប់កម្មវិធីសុខាភិបាលសាធារណៈសំខាន់ៗនៅរដ្ឋ California ប្រឈមនឹងហានិភ័យ រួមមាន ការតាមដានជំងឺ ការត្រៀមលក្ខណៈសម្រាប់គ្រាអាសន្ន ការបង្ការមេរោគ HIV ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការចាក់វ៉ាក់សាំង សមត្ថភាពមន្ទីរពិសោធ និងការបង្ការនៅតាមសហគមន៍។ បញ្ហាប្រឈមទាំងនេះមានវិសាលភាពលើសពីការស្រាវជ្រាវផ្នែកជីវវេជ្ជសាស្ត្រយ៉ាងច្រើន។

ប្រសិនបើរដ្ឋ California ជ្រើសរើសបំពេញជំនួសការគាំទ្រពីរដ្ឋាភិបាលសហព័ន្ធដែលកំពុងថយចុះ មន្ត្រីជាប់ឆ្នោតគួរតែអាចពិចារណាអាទិភាពផ្នែកសុខាភិបាលទាំងអស់រួមគ្នា។ ផ្ទុយទៅវិញ សំណើទី 38 បែងចែកប្រាក់ដែលបានខ្ចីរាប់ពាន់លានដុល្លារដែលបានកំណត់ទុកសម្រាប់វិស័យវិទ្យាសាស្ត្រតែមួយ ដោយមិនគិតពីតម្រូវការ ឬការរកឃើញថ្មីៗនៅពេលអនាគតឡើយ។ អាទិភាពនៃការស្រាវជ្រាវគួរតែត្រូវបានណែនាំតាមរយៈដំណើរការរៀបចំថវិកាធម្មតា មិនមែនតាមរយៈវិធានការសន្លឹកឆ្នោត ដែលធ្វើឱ្យអ្នកជាប់ពន្ធត្រូវជាប់កាតព្វកិច្ចបំណុលអស់រយៈពេលជាច្រើនទសវត្សរ៍នោះទេ។ បោះឆ្នោត *ទេ* លើសំណើទី 38។

**Robert M Kaplan**, Ph.D.

 អំណះអំណាងដែលបោះពុម្ពនៅលើទំព័រនេះគឺជាមតិរបស់អ្នករៀបរៀង ហើយមិនត្រូវបានត្រួតពិនិត្យភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយឡើយ។

## ★ អំណះអំណាងប្រឆាំងសំណើទី 38 ★

រដ្ឋ California ទទួលស្គាល់ថា ការបន្តវិនិយោគលើវិទ្យាសាស្ត្រគឺមានភាពចាំបាច់។ ប៉ុន្តែ សំណើនេះមិនមែនជាមធ្យោបាយល្អបំផុតដើម្បីសម្រេចគោលដៅនោះទេ។

វិធានការនេះនឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់ប្រមាណ $8.4 ពាន់លាន ដើម្បីគាំទ្រការស្រាវជ្រាវផ្នែកប្រព័ន្ធភាពស៊ាំ និងការព្យាបាលដោយប្រើប្រព័ន្ធភាពស៊ាំ តាមរយៈវិទ្យាស្ថានរបស់សាកលវិទ្យាល័យ California ថ្មីមួយ។ ទោះបីជាគោលបំណងនេះគួរឱ្យចាប់អារម្មណ៍ក៏ដោយ ក៏ក្របខណ្ឌហិរញ្ញប្បទាន និងគោលនយោបាយមានចំណុចខ្វះខាតដែរ។

ដំបូង សំណើនេះបន្តការប្រើប្រាស់គំនិតផ្តួចផ្តើមនៃសន្លឹកឆ្នោត ដើម្បីដឹកនាំមូលនិធិស្រាវជ្រាវទៅកាន់ប្រធានបទដែលបានជ្រើសរើស។ រដ្ឋ California បានបង្កើតកម្មវិធីផ្តល់មូលនិធិដាច់ដោយឡែករួចហើយ សម្រាប់ការស្រាវជ្រាវកោសិកាចម្បង និងឱសថជាក់លាក់។ វិធានការនេះនឹងបន្ថែមកម្មវិធីដែលត្រូវផ្តោតលើយ៉ាងខ្លាំងមួយទៀត។ អាទិភាពនៃការស្រាវជ្រាវគួរតែត្រូវបានបង្កើតតាមរយៈការពិនិត្យផ្នែកវិទ្យាសាស្ត្រ និងការរៀបចំផែនការសុខាភិបាលសាធារណៈ មិនមែនតាមរយៈយុទ្ធនាការឃោសនាបោះឆ្នោតនោះទេ។ ជំងឺមហារីក ជំងឺ Alzheimer's និងជំងឺបេះដូង សុទ្ធតែសាកសមទទួលបានការយកចិត្តទុកដាក់ ប៉ុន្តែជំងឺផ្លូវចិត្ត ជំងឺតម្រងនោម ជំងឺភ្នែក និងជំងឺជាច្រើនផ្សេងទៀត ក៏ដូចគ្នាផងដែរ។ ការកំណត់ទិសដៅវិទ្យាសាស្ត្រតាមរយៈការប្រើសន្លឹកឆ្នោត ជៀសមិនរួចនឹងផ្តល់អាទិភាពដល់ប្រធានបទដែលទទួលបានការចាប់អារម្មណ៍ខ្លាំងបំផុត ជាជាងឱកាសស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រដែលមានសក្តានុពលខ្ពស់បំផុត ឬតម្រូវការផ្នែកសុខាភិបាលសាធារណៈដែលមានសារៈសំខាន់បំផុត។

ទីពីរ ការខ្ចីប្រាក់ជាមធ្យោបាយមិនសមស្របសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រទេ។ យោងតាមការិយាល័យអ្នកវិភាគផ្នែកនីតិបញ្ញត្តិ មូលបត្របំណុលដែលត្រូវបានអនុញ្ញាតដោយសំណើនេះនឹងធ្វើឱ្យអ្នកជាប់ពន្ធត្រូវបង់បំណុលចំនួន $500 លានក្នុងមួយឆ្នាំ សម្រាប់រយៈពេលប្រមាណ 25 ឆ្នាំ។ មូលបត្របំណុលជាទូទៅត្រូវបានប្រើសម្រាប់ផ្តល់ហិរញ្ញប្បទានដល់ផ្លូវល្បឿនលឿន សាលារៀន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតដែលមានអាយុកាលប្រើប្រាស់យូរ និងផ្តល់អត្ថប្រយោជន៍ដែលអាចព្យាករណ៍ទុកជាមុនបាន។ ការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រមានលក្ខណៈខុសគ្នា។ របកគំហើញថ្មីៗតែងតែត្រូវការពេលរាប់ទសវត្សរ៍ មុនពេលអាចនាំឱ្យមានការកែលម្អការថែទាំអ្នកជំងឺបានប្រសើរ ហើយក្តីសង្ឃឹមនៃការសិក្សាស្រាវជ្រាវមិនដែលនាំទៅរកការបង្កើតការព្យាបាលដែលអាចដាក់លក់ក្នុងទីផ្សារបានឡើយ។

ទីបី សំណើនេះសន្មតថា របកគំហើញថ្មីៗដែលទទួលបានជោគជ័យ នឹងបង្កើតចំណូលបានគ្រប់គ្រាន់ ដើម្បីទូទាត់ការចំណាយរបស់រដ្ឋ។ តាមការជាក់ស្តែង សាកលវិទ្យាល័យកម្រផ្សព្វផ្សាយវិធីព្យាបាលថ្មីៗដោយខ្លួនឯងណាស់។ មូលនិធិសាធារណៈស្រាវជ្រាវ ជួយបង្កើតមូលដ្ឋានវិទ្យាសាស្ត្រ ប៉ុន្តែក្រុមហ៊ុនឯកជនតែងតែវិនិយោគធនធានយ៉ាងច្រើន តម្រូវសម្រាប់ការអភិវឌ្ឍផលិតផល ការធ្វើតេស្តគ្លីនិក សង្វាក់ផលិតកម្ម និងការអនុម័តបទបញ្ញត្តិ។ អត្ថប្រយោជន៍សាធារណៈគឺមានពិតប្រាកដ ប៉ុន្តែជាទូទៅ អត្ថប្រយោជន៍ទាំងនោះមិនត្រឡប់មកកាន់ថវិការដ្ឋវិញនោះទេ។

ចុងក្រោយ សំណើនេះតម្រូវឱ្យវិធីព្យាបាលច្បាស់លាស់មួយចំនួនដែលត្រូវបានអភិវឌ្ឍដោយមានការគាំទ្រពីរដ្ឋ ដើម្បីអាចដាក់លក់នៅក្នុងរដ្ឋ California ក្នុងការបញ្ចុះតម្លៃ។ ទោះបីជាគំនិតនេះអាចស្តាប់ទៅគួរឱ្យទាក់ទាញក៏ដោយ វាអាចជំរុញឱ្យក្រុមហ៊ុនផ្តល់អាទិភាពដល់ការលក់ផលិតផលទាំងនេះនៅរដ្ឋផ្សេងទៀត ដែលមិនមានការគ្រប់គ្រងតម្លៃ។

រដ្ឋ California គួរតែបន្តគាំទ្រការស្រាវជ្រាវផ្នែកជីវវេជ្ជសាស្ត្រ។ ប៉ុន្តែ ការផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវគួរតែមានផែនការយុទ្ធសាស្ត្រ មានភាពបត់បែន និងមានការទទួលខុសត្រូវសារពើពន្ធ។ ការសម្រេចចិត្តអំពីអាទិភាពផ្នែកវិទ្យាសាស្ត្រ គួរតែផ្អែកលើការវាយតម្លៃរបស់អ្នកជំនាញអំពីការរួមបញ្ចូលឱកាសវិទ្យាសាស្ត្រនានា និងតម្រូវការផ្នែកសុខាភិបាលសាធារណៈ មិនមែនលើវិធានការសន្លឹកឆ្នោតជាបន្តបន្ទាប់ដែលមានការចំណាយខ្ពស់ ផ្អែកលើហិរញ្ញប្បទានរយៈពេលវែងនោះទេ។

រដ្ឋ California មានជម្រើសនានាដែលល្អប្រសើរជាងនេះ។ ឧទាហរណ៍ សមាជិកព្រឹទ្ធសភា Scott Wiener បានស្នើឱ្យបង្កើតទីភ្នាក់ងារស្រាវជ្រាវមួយដែលទទួលមូលនិធិពីរដ្ឋ ដោយយកទីភ្នាក់ងារ វិទ្យាស្ថានជាតិសុខាភិបាល និងមូលនិធិវិទ្យាសាស្ត្រជាតិជាគំរូ។ ជំនួសឱ្យការដឹកនាំធនធានទៅកាន់ផ្នែកជាក់លាក់ណាមួយនៃវិទ្យាសាស្ត្រ ស្ថាប័នបែបនេះអាចដាក់ចេញអាទិភាពតាមរយៈការពិនិត្យវាយតម្លៃដោយអ្នកជំនាញផ្នែកវិទ្យាសាស្ត្រ ហើយអាចកែសម្រួលការវិនិយោគរបស់ខ្លួនទៅតាមឱកាសថ្មីៗលេចឡើង។ ទោះបីជានីតិបញ្ញត្តិមិនទាន់មានការរីកចម្រើនទៅមុខក៏ដោយ ក៏វាទទួលបានការគាំទ្រពីសាកលវិទ្យាល័យ California សហជីពកម្មករយានយន្ត និងសហជីពគ្រូពេទ្យ និងទន្តពេទ្យអាមេរិក។ នីតិបញ្ញត្តិដែលមានលក្ខណៈស្រដៀងគ្នានេះ ទំនងជានឹងត្រូវបានពិចារណានៅពេលអនាគត។

ការបោះឆ្នោត"ទេ" មិនមែនមានន័យថា ប្រឆាំងនឹងវិទ្យាសាស្ត្រនោះទេ។ វាប្រឆាំងនឹងយន្តការផ្តល់ហិរញ្ញប្បទានដែលមិនមានប្រសិទ្ធភាព និងវិធីសាស្ត្រដែលបែកខ្ញែកក្នុងការកំណត់អាទិភាពនៃការស្រាវជ្រាវ។ រដ្ឋ California អាច និងគួរតែគាំទ្រការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ តាមរយៈគោលនយោបាយដែលមានការសម្របសម្រួលកាន់តែប្រសើរ និងមាននិរន្តរភាព។

**Robert M Kaplan**, Ph.D.

## ★ ការបដិសេធចំពោះអំណះអំណាងប្រឆាំងសំណើទី 38 ★

ការបោះឆ្នោត "បាទ/ចាស" លើសំណើទី 38 មានសារៈសំខាន់យ៉ាងខ្លាំង ដើម្បីគាំទ្រការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រអំពីប្រព័ន្ធភាពស៊ាំ ដែលអាចជួយសង្គ្រោះជីវិត

សព្វថ្ងៃនេះ របកគំហើញការព្យាបាលដោយប្រព័ន្ធភាពស៊ាំដ៏សំខាន់ កំពុងព្យាបាលជំងឺមហារីកមួយចំនួនឱ្យជាសះស្បើយរួចហើយ ដូចជា មហារីកស្បែកប្រភេទកម្រក៏សាហាវ មហារីកសួត និងជំងឺមហារីកឈាម។ បច្ចុប្បន្ន កំពុងមានការស្រាវជ្រាវដែលមានសក្តានុពល ដើម្បីស្វែងរកវិធីព្យាបាល និងការពារជំងឺដូចជា ជំងឺ Alzheimer's ជំងឺបេះដូង ជំងឺ Parkinson 's, ជំងឺ ALS និងជំងឺផ្សេងៗទៀត។

ការកាត់បន្ថយមូលនិធិរបស់រដ្ឋាភិបាលសហព័ន្ធយ៉ាងច្រើន កំពុងគំរាមកំហែងដល់ការរីកចម្រើនឆ្ពោះទៅរកការរកឃើញវិធីព្យាបាលដែលអាចជួយសង្គ្រោះជីវិតបាន។

ការបោះឆ្នោត "បាទ/ចាស" លើសំណើទី 38 នឹងធានាថា សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវមិនរកប្រាក់ចំណេញនៅរដ្ឋ California អាចបន្តការស្រាវជ្រាវផ្នែកប្រព័ន្ធភាពស៊ាំដែលមានសារៈសំខាន់ និងចាំបាច់យ៉ាងខ្លាំង ដើម្បីព្យាបាល និងបង្ការជំងឺដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរបំផុត។

*"ប្រព័ន្ធភាពស៊ាំបានជួយសង្គ្រោះជីវិតខ្ញុំ—ឥឡូវនេះ ខ្ញុំគ្មានជំងឺមហារីកទៀតទេ ហើយវាក៏អាចជួយសង្គ្រោះជីវិតមនុស្សរាប់លាននាក់ទៀតបានផងដែរ។"*

—Andrew Dale, អ្នកជំងឺដែលបានទទួលការព្យាបាលដោយប្រើប្រព័ន្ធភាពស៊ាំ និងជាអ្នករស់រានពីជំងឺមហារីក។

ការបោះឆ្នោត "បាទ/ចាស" លើសំណើទី 38 ត្រូវបានរៀបចំឡើងដើម្បីឱ្យវាអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីរ៉ាប់រងការចំណាយរបស់ខ្លួន ដោយមិនបង្កើតការចំណាយបន្ថែមសម្រាប់អ្នកជាប់ពន្ធ។

ដប់ភាគរយ (10%) នៃប្រាក់ចំណូលពីការផ្តល់អាជ្ញាបណ្ណសម្រាប់ការព្យាបាលដោយប្រើប្រព័ន្ធភាពស៊ាំ ត្រូវបង្វិលត្រឡប់ទៅរដ្ឋ California វិញ ដើម្បីជួយទូទាត់ចំណាយលើមូលបត្របំណុល។ លក្ខខណ្ឌតម្រូវទាំងនេះត្រូវបានកំណត់នឹងវិធានការនេះដោយមិនអាចកែប្រែបាន។

ការបោះឆ្នោត "បាទ/ចាស" លើសំណើទី 38 តម្រូវឱ្យមានការទទួលខុសត្រូវ និងតម្លាភាពយ៉ាងខ្លាំង

- កំណត់ការចំណាយរដ្ឋបាលរបស់រដ្ឋមិនឱ្យលើស 2%
- ការបង្ហាញជាសាធារណៈអំពីការចំណាយ
- ការធ្វើសវនកម្មហិរញ្ញវត្ថុដោយឯករាជ្យ

ការបោះឆ្នោត "បាទ/ចាស" លើសំណើទី 38 ជួយកាត់បន្ថយការចំណាយលើសេវាថែទាំសុខភាព

ការព្យាបាលដោយប្រើប្រព័ន្ធភាពស៊ាំដែលត្រូវបានអភិវឌ្ឍតាមរយៈសំណើទី 38 ត្រូវតែផ្តល់ជូនអ្នកជំងឺនៅរដ្ឋ California ក្នុងតម្លៃបញ្ចុះ 20%។ ការបង្ការ និងព្យាបាលជំងឺឱ្យជាសះស្បើយក៏នឹងជួយឱ្យគ្រួសារ និងរដ្ឋសន្សំប្រាក់រាប់ពាន់លានដុល្លារលើការចំណាយថែទាំសុខភាពក្នុងរយៈពេលវែងផងដែរ។

វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងអ្នកតស៊ូមតិដើម្បីអ្នកជំងឺ អំពាវនាវឱ្យបោះឆ្នោត បាទ/ចាស លើសំណើទី 38

- សមាគម Alzheimer's • សមាគមគិលានុបដ្ឋាកអាមេរិក/California • សមាគម ALS
- សមាគមជំងឺមហារីកតម្រងនោម • សម្ព័ន្ធស្រាវជ្រាវជំងឺមហារីកស្បែកប្រភេទកម្រដ៏សាហាវ
- សមាគមជាតិជំងឺពិការប្រព័ន្ធសរសៃប្រសាទ MS • មូលនិធិ Michael J. Fox សម្រាប់ការស្រាវជ្រាវជំងឺ Parkinson's ... និងជាច្រើនទៀត។

គាំទ្រវិធីព្យាបាលដែលអាចជួយសង្គ្រោះជីវិត។ សូមបោះឆ្នោត បាទ/ចាស លើសំណើទី 38។

*www.YesOn38.com*

**Andrew Dale**, អ្នកជំងឺរស់រានពីជំងឺមហារីក
Santa Monica

**Anne M. Holloway**, សមាជិកក្រុមប្រឹក្សាភិបាល
មូលនិធិ Michael J. Fox សម្រាប់ការស្រាវជ្រាវជំងឺ Parkinson's

**Chris Tarver**, R.N., ប្រធាន
សមាគមគិលានុបដ្ឋាកអាមេរិក/California

38